បាងកក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## សមាជចុងក្រោយនៃគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ (DELGOSEA)៖ ដំណើរទៅកាន់អភិបាលកិច្ចបែបប្រជាធិបតេយ្យនៅមូលដ្ឋាននៅតែបន្ត

បណ្តាញ**គម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍** (DELGOSEA)កំពុងតែ ជម្រុញឱ្យមានការបង្កើតនូវវេទិកាពិភាក្សាមួយមានលក្ខណៈអចិន្ត្រៃស្តីពីវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន រវាង ប្រទេសជាសមាជិកអាស៊ាន និងសម្រាប់ការពង្រីកកិច្ចហាការណ៍ជាមួយនឹងរដ្ឋអំណាចមូលដ្ឋាន និងសង្គមស៊ីវិល តាមអភិក្រមសហអ្នកពាក់ព័ន្ធ។ អាស៊ាន បានទទួលស្គាល់ ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការស្តីពី អភិបាលកិច្ចមូលដ្ឋានក្នុងគោលបំណងធានាឱ្យមានស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងប្រទេសអាស៊ីភាគអាគ្នេយ៍បានប្រសើរឡើង និងការគាំទ្រដល់អភិក្រមរួមគ្នារវាងប្រទេសជាសមាជិកក៏កំពុងតែរីកចម្រើនផងដែរ។



Konrad-Adenauer-Stiftung e.V. Head Office Germany

Field office Philippines5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines

Delegation of the European Union to Indonesia and Brunei Darussalam
Intiland Tower, 16th floor
Jl Jend Sudirman 32
Jakarta 10220 Indonesia
Tel: (62 21) 2554 6200
Fax:(62 21) 2554 6201

The European Commission is the EU's executive body.

The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.

DELGOSEA
Partnership for Democratic Local Governance in Southeast-Asia



អភិបាលកិច្ចក្នុងក្របខ័ណ្ឌ អាស៊ាន។ សមាជនេះនឹងប្រារព្វធ្វើឡើងនៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ នាថ្ងៃអង្គារ៍ និងពុធទី៧ និងទី៨ ខែសីហា ឆ្នាំ២០១២ ដែលបង្ហាញពីសញ្ញាណនៃការបញ្ចប់គម្រោងដែលមានការផ្តល់សហហិរញ្ញប្បទានពីសហគមអឺរ៉ុប។ សមាជនេះត្រូវបានធ្វើជាម្ចាស់ផ្ទះដោយសម្ព័ន្ធភាពទីក្រុងរបស់ថៃ(MLT) និង Konrad-Adenauer-Stiftung(KAS)តំណាងឱ្យគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន នៅអាស៊ីអាគ្នេយ៍ (DELGOSEA) និងមានចូលរួមជាង១៥០នាក់ ជាតំណាងដៃគូគម្រោង សមាគមរដ្ឋបាលមូលដ្ឋាន បណ្តាទីក្រុងចូលរួមសាកល្បងអនុវត្តបទពិសោធន៍ល្អៗ ស្ថាប័នអប់រំ សារព័ត៌មាន រដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការសង្គមស៊ីវិលនានា។

សមាជនឹងធ្វើការផ្តោតអារម្មណ៍ទៅលើនិរន្តរភាពនៃលទ្ធផលគម្រោង និងលទ្ធភាពពង្រឹងបណ្តាញនាពេលអនាគត។ សមាជមានគោលបំណងអភិវឌ្ឍយុទ្ធសាស្ត្រមួយសម្រាប់វេទិកាពិភាក្សាមួយមានលក្ខណ:អចិន្ត្រៃស្តីពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យក្នុងកំរិតតំបន់អាស៊ាន។ អ្នកចូលរួមនឹងពិនិត្យមើលផងដែរដើម្បីរៀបចំយុទ្ធសាស្ត្រដកថយក្នុងន័យរក្សាបាននូវចីរភាពនៃលទ្ធផលគម្រោង។

កិច្ចការសំខាន់មួយទៀត គឺការពិនិត្យមើលស្ថាប័ន និងអង្គការនានា ដែលអាច និងមានបំណងផ្តល់ប្រព័ន្ធគាំទ្រដល់ទីក្រុង៖ ជាសមាគមអាជ្ញាធរមូលដ្ឋាន សមាគមថ្នាក់តំបន់ដូចជា

United Cities and Local Governments (UCLG) សហាគមអឺរ៉ុប គណៈកម្មាធិការនានាក្នុងតំបន់ ។ល។ សមាជនឹងធ្វើការពិភាក្សាលើតួនាទីនៃស្ថាប័នទាំងនោះ និងថាតើស្ថាប័ននានាទាំងនោះនឹងអាចចូលរួមដល់ការពង្រឹងអភិបាលកិច្ចល្អមូលដ្ឋាន នៅតំបន់អាស៊ីភាគអាគ្នេយ៍យ៉ាងដូចម្ដេច។

តាមប្រសាសន៍របស់អ្នកស្រី Susanne Stephan នាយកគម្រោងគឺថា "*សមាជចុងក្រោយនេះ គឺមិនមែនជាដំណាក់បញ្ចប់នោះទេ តែគ្រាន់តែជាការបញ្ចប់ជំពូកមួយ និងចាប់ផ្ដើមជំពូកថ្មីមួយតែប៉ុណ្ណោះ*" ។ គាត់បន្ថែមថា "*សមាជជាឱកាសដើម្បីពិនិត្យមើលនូវអ្វីដែលសម្រេចបាន និងក្នុងពេលតែមួយ យើងអាចពិភាក្សាលើផែនទីបង្ហាញផ្លូវសម្រាប់ការរៀនសូត្របន្ថែមទៀត និងផ្លាស់ប្ដូររវាងរដ្ឋបាលមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ ក៏ដូចជាពង្រឹងនូវតួនាទីរបស់ខ្លួនក្នុងកំរិតថ្នាក់តំបន់នាពេលអនាគត*" ។ នាយកគម្រោងបន្ថែមថា "*ពីរឆ្នាំកន្លះនៃជោគជ័យបានកន្លងផុតទៅ ហើយបណ្ដាឆ្នាំជោគជ័យប្រសើរជាងនេះស្ថិតនៅពីមុខយើង*"។

ចប់

Konrad Adenauer Stiftung
UCLG ASPAC
LOCAL GOVERNMENT DEVELOPMENT FOUNDATION

A project implemented by the contractor

This project is co-funded by the European Union

www.DELGOSEA.eu

Konrad-Adenauer-Stiftung e.V. Head Office Germany

Field office Philippines5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines

Delegation of the European Union to Indonesia and Brunei Darussalam
Intiland Tower, 16th floor
Jl Jend Sudirman 32
Jakarta 10220 Indonesia
Tel: (62 21) 2554 6200
Fax:(62 21) 2554 6201

The European Commission is the EU's executive body.

The European Union is made up of 27 Member States who have decided to gradually link together their know-how, resources and destinies. Together, during a period of enlargement of 50 years, they have built a zone of stability, democracy and sustainable development whilst maintaining cultural diversity, tolerance and individual freedoms. The European Union is committed to sharing its achievements and its values with countries and peoples beyond its borders.

### អំពីគម្រោងDELGOSEA

ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (DELGOSEA)បង្កើតបណ្តាញ៣២ទីក្រុង និង ខេត្តនានា ដើម្បីអនុវត្តតាមការអនុវត្តល្អនៃអភិបាលកិច្ចអន្តរតំបន់ទៅដល់ប្រទេសជាដៃគូនានា ដូចជា កម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម។ បណ្តាញនេះត្រូវបានគាំទ្រដោយសមាគមរដ្ឋាភិបាលមូលដ្ឋានចំនួន១១ រដ្ឋអំណាចមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិ-បាល និងវិទ្យាស្ថានអប់រំនិងបណ្តាញសារព័តមាននានា និង គាំទ្រតួនាទីក្នុងការផ្តល់ឲ្យ និង ជួយដល់ការផ្ទេរ និង និរន្តរភាពនៃការអនុវត្តតាមការអនុវត្តល្អនៃអភិបាលកិច្ចមូលដ្ឋាន និង ត្រូវបានគ្រប់គ្រងដោយអង្គការខុនរ៉ាដ Konrad-Adenauer-Stiftung(KAS) សហការឧបត្ថម្ភដោយសហភាពអឺរ៉ុប នៃប្រទេសអាឡឺម៉ង់ តាមរយៈក្រសួងនៃសហប្រតិបត្តិការការអភិវឌ្ឍន៍របស់ប្រទេសអាឡឺម៉ង់។

គម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (DELGOSEA)

**Contact person:**

Ms Susanne Stephan
Project Manager
Susanne.Stephan@DELGOSEA.eu
+ 63.2.4036797

សម្រាប់ព័ត៌មានបន្ថែមពីសមាជចុងក្រោយនិងលទ្ធផលនៃសមាជ សូមមើលគេហទំព័រ www.DELGOSEA.eu